ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រៃវែង**

សំណុំរឿងរដ្ឋប្បវេណីលេខ ៤៣៣

ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៨

សាលក្រមលេខ ១៤៤/៥៤ "ក"

ចុះថ្ងៃសុក្រ ៥កើត ខែមិគសិរ ឆ្នាំជូត

ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី

២០ ខែវិច្ឆិកា ឆ្នាំ២០២០

# លិខិតសាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តព្រៃវែង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ នៅសាលសវនាការសាលាដំបូងខេត្តព្រៃវែង ដែលសមាសភាពជំនុំជម្រះមានដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តព្រៃវែង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ៤៣៣ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ដែលមានវិវាទរវាង ៖

គូភាគី:

ដើមចោទ ៖ ឈ្មោះ [redacted] **សុខា** ភេទស្រី អាយុ៥០ឆ្នាំ កើតឆ្នាំ១៩៧០ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរលក់បាយម្ហូប អាសយដ្ឋានបច្ចុប្បន្នភូមិ [redacted] ឈ្មោះ [redacted] **អូន** មានកូន០១នាក់ ។

មេធាវីតំណាងដោយអាណត្តិលោក [redacted] [illegible]៦ ។

ចុងចម្លើយ ៖ អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង ។

អ្នកតំណាង:

១-លោក [redacted] សុជា ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ជាប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រៃវែង អាសយដ្ឋានបច្ចុប្បន្ន [redacted] ។

២-លោក [redacted] វ៉ន ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ជាអនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រៃវែង អាសយដ្ឋានបច្ចុប្បន្ន [redacted] ។

៣-លោក [redacted] សុខជា ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ជានាយកទីចាត់ការអន្តរវិស័យសាលាខេត្តព្រៃវែង អាសយដ្ឋានបច្ចុប្បន្ន [redacted] ។

មេធាវីតំណាងដោយអាណត្តិ គ្មាន ។

## ១.អង្គហេតុ និង ចំណុចវិវាទ

### ក.ខ្លឹមសារសាលក្រមដែលដើមចោទទាមទារ:

**ដើមចោទប្ដឹងសុំឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម:**

**- បដិសេធលិខិតជូនដំណឹងលេខ ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង ។**

### ១. ដំណើររឿង និងចំណុចវិវាទ

#### ១-១. អង្គហេតុចាំបាច់ដែលជាមូលដ្ឋាននៃការទាមទារ:

មូលដ្ឋាននៃការទាមទាររបស់ដើមចោទ គឺផ្អែកតាមការអះអាងរបស់ខ្លួន និងសាក្សី

#### ១-២.សេចក្តីសង្ខេបនៃរឿងក្តី:

រឿងក្តីនេះអ្នកស្រី [redacted] សុខា ជាដើមចោទ បានប្តឹងទាមទារឲ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារដូចខាងលើ ដោយសំអាងហេតុថា ដីទំហំ២០មX៣៤ម ស្ថិតនៅចំណុចភូមិ២ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង មុំស្ថានីយប្រេងឥន្ធនៈជិតផ្សារអ្នកលឿង ដែលឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ដាក់ធ្វើជាបេនចំណតរថយន្តនោះ គឺមិនត្រឹមត្រូវនោះទេ ដោយហេតុថា ដីនេះជាដីកម្មសិទ្ធិរបស់ខ្លួន ដោយខ្លួនបានមករកស៊ីលក់ដូរបាយម្ហូប តាំងពីឆ្នាំ១៩៨២ តាំងពីមិនទាន់មានផ្សារនៅឡើយ ដោយផ្សារទើបតែបង្កើតនៅឆ្នាំ១៩៩៦ ហើយពេលដែលខ្លួនមកលក់សូម្បីតែស្ថានីយប្រេងក៏មិនទាន់មានដែរ ។

#### ១.៣. អង្គហេតុមិនមានវិវាទ

ដើមចោទបានសង់រោងលក់ដូរនៅលើដីទំហំ២០មX៣៤ម ស្ថិតនៅចំណុចភូមិ២ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង មុំស្ថានីយប្រេងឥន្ធនៈជិតផ្សារអ្នកលឿង ហើយអ្នកតំណាងឲ្យចុង

ចម្លើយក៏បានទទួលស្គាល់ដែរ ដើមចោទពិតជាសង់ពេងលក់ដូរនៅលើដីនេះប្រាកដមែន ។

១-៤.ចំណុចវិវាទ

-ថាតើរាល់អង្គហេតុដែលអះអាងដោយដើមចោទពិតជាមានអត្ថិភាព បញ្ជាក់ឲ្យឃើញថា ការទាមទារឲ្យតុលាការលុបចោលលិខិតជូនដំណឹងលេខ ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង អាចទទួលបានដែរឬទេ ។

**១.៥. ការអះអាងរបស់គូភាគី**

**១.៥.១. សេចក្ដីថ្លែងការណ៍របស់ដើមចោទ**

ដើមចោទឈ្មោះ [redacted] **សុខា** បានធ្វើការអះអាងថា: ខ្លួនស្នើសុំឲ្យតុលាការបដិសេធលិខិតជូនដំណឹងលេខ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង ចោលទាំងស្រុង ដោយហេតុថា ដីទំហំ២០មx៣៤ម ស្ថិតនៅចំណុចភូមិ២ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង មុំស្ថានីយប្រេងជិតផ្សារអ្នកលឿង ដែលឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រៃវែង ដាក់ធ្វើជាបេទចំណតនោះ គឺមិនត្រឹមត្រូវនោះទេ ដោយហេតុថា ដីនេះជាដីកម្មសិទ្ធិរបស់ខ្លួន ដោយខ្លួនបានមករកស៊ីលក់ដូរបាយម្ហូប តាំងពីឆ្នាំ១៩៨៤ តាំងពីមិនទាន់មានផ្សារនៅឡើយ ដោយផ្សារទើបតែបង្កើតនៅឆ្នាំ១៩៩៦ ហើយពេលដែលខ្លួនមកលក់សូម្បីតែស្ថាននីយប្រេងក៏មិនទាន់មានដែរ ។

ខ្លួនមិនប្រគល់ដីទំហំដីទំហំ២០មx៣៤ម ស្ថិតនៅចំណុចភូមិ២ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង មុំស្ថានីយប្រេងជិតផ្សារអ្នកលឿង ជូនទៅរដ្ឋនោះទេ ដោយហេតុថា ដីនោះជាដីកម្មសិទ្ធិរបស់ខ្លួន ។

ដីនេះជាដីដែលខ្លួនចាប់នៅតាំងពីឆ្នាំ១៩៨៤ ហើយពេលខ្លួនមករស់នៅដំបូងជាជង្ហុកជ្រៅ ដោយខ្លួនចេះតែចាក់ដីលុបរហូតបានមកដល់ពេលនេះ ។

ខ្លួនមិនដឹងរឿងច្បាប់ទម្លាប់អ្វីទេ គឺខ្លួនដឹងតែម្យ៉ាង គឺខ្លួនរស់នៅលើដីនេះតាំងតែពីឆ្នាំ១៩៨៤ មកតាំងតែពីមិនទាន់មានបេទចំណតនេះមកម្ល៉េះ ។

ចំពោះអ្នកដែលរស់នៅប៉ែកខាងជើង គឺពួកគាត់រំលោភបំពានលើដីរដ្ឋ ដីថ្នល់ និងដីលូ ។

**សំណូមពរ:** បដិសេធលិខិតជូនដំណឹងលេខ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង ។

លោកមេធាវីតំណាងអាណត្តិឲ្យដើមចោទ បានធ្វើសេចក្ដីថ្លែងការណ៍បន្ថែមថា ដោយហេតុថាមានសជណ ទើបកូនក្ដីខ្លួនប្ដឹង ។ សជណ ពុំមានលក្ខណៈសម្បត្តិគតិយុត្តទាក់ទងទៅនឹងដីរបស់កូនក្ដីខ្លួនកាន់កាប់នោះទេ ។ ដីនេះកូនក្ដីខ្លួនគាត់បានកាប់កាប់តាំងពីឆ្នាំ១៩៨៤ តាំងពីមិនទាន់បង្កើតផ្សារ



Scanned with CamScanner

អ្នកលឿង ដោយផ្សារទើបតែបង្កើត និងភាស៊ីផ្សារ ។ ដីនៅទីនោះជាដីកម្មសិទ្ធិឯកជន គឺមានគេសង់សំណង់រស់នៅ ជាពិសេសការ៉ាស់សាំង និងសណ្ឋាគារសុវណ្ណពេជ្រ ដែលបានសង់សំណង់រឹងមាំ ធ្វើលូបង្ហូរទឹកធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរកន្លែងនោះ ។

ខ្ញុំបាទស្នើសុំឲ្យតុលាការសម្រេចសេចក្តីទៅតាមផ្លូវច្បាប់ និងសម្រេចឲ្យកូនក្តីខ្លួនបានរស់នៅទីនោះបន្តទៀត ទោះបីជាដីសាធារណៈរបស់រដ្ឋក៏ដោយ ក៏រដ្ឋមានការអនុគ្រោះនោះដែរ ។

ដីនេះបើមានប័ណ្ណកម្មសិទ្ធិរបស់រដ្ឋ គួតែឲ្យតំណាងមកជជែកវែកញែកពីផ្លូវច្បាប់ ផ្តល់ហេតុផលសមស្របដល់កូនក្តីរបស់ខ្លួន ។ កូនក្តីខ្លួនជាស្រីមេម៉ាយ និងមានកូនម្នាក់នៅក្នុងបន្ទុកទៀតផង។ ទីតាំងដីទំនាស់តាមការពិនិត្យជាក់ស្តែងឃើញថា នៅជុំវិញមានការសង់ការ៉ាស់សាំង សណ្ឋាគារ និងផ្ទះ ហើយការមករស់នៅរបស់កូនក្តីខ្លួនតាំងពីឆ្នាំ១៩៨៤ និងមានការចំណាយប្រាក់កាសក្នុងការចាក់ដីជង្ហុកតាំងពីក្រោមរហូតមកដល់លើ ។

**១.៥.២.ការអះអាងរបស់សហចុងចម្លើយ:**

អ្នកតំណាងលោក [redacted] វ៉ន បានធ្វើការអះអាងថា តាមលិខិតលេខ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង បានជូនដំណឹងទៅឈ្មោះ [redacted] សុខា ឲ្យធ្វើការឈូសឆាយដីដែលបានចាក់បំពាននៅចំណតរថយន្ត នៅចន្លោះស្ពាននីយ៍ប្រេងឥន្ទនៈ មុខសណ្ឋាគារ សុវណ្ណពេជ្រ ដោយហេតុថា ឈ្មោះ [redacted] សុខា បានចាក់ដីនៅលើទីតាំងចំណតរថយន្ត មិនអាចឲ្យឡានចូលចតបាន និងធ្វើឲ្យទឹកហៀរទៅលើផ្ទះប្រជាពលរដ្ឋ ដែលរស់នៅប៉ែកខាងជើង ។

ពាក់ព័ន្ធនឹងដីបេនចំណតរថយន្តទំហំ២០ម×៣៤ម នៅចន្លោះស្ពាននីយ៍ប្រេងឥន្ទនៈ មុខសុវណ្ណពេជ្រ ស្ថិតនៅចំណុចភូមិ៤ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង នេះ ពីដើមឡើយរដ្ឋបាលខេត្តព្រៃវែង បានចុះបញ្ជីជាចំណតរថយន្តជើងគោក តាមដីកាស្តីពីការកំណត់ទីតាំងចំណតជើងគោកជើងទឹកអ្នកលឿងលេខ ៧៥/២០០៣ ដ.ក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៣ និងគំនូសព្រាងចំណតរថយន្តចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៣ ។

នៅឆ្នាំ២០០៥ លោកឧកញ៉ា [redacted] ភាព និងលោក [redacted] គង់ បានដាក់សំណើសុំដាក់ទុនសាងសង់ស្ពានមួយកន្លែងស្ថិតនៅចំណុចព្រែកជំ ក្នុងភូមិព្រែកតាស ឃុំអ្នកលឿង ដោយធ្វើការរំលោះទុនមកវិញតាមរយៈធ្វើអាជីវកម្មចំណតជើងគោកជើងទឹកអ្នកលឿង ហើយតាមលិខិតលេខ១៨៩៩ សជណ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី បានអនុញ្ញាតិឲ្យលោកឧកញ៉ា [redacted] ភាព និងលោក [redacted] គង់ ធ្វើវិនិយោគរួមគ្នាក្នុងការធ្វើអាជីវកម្មចំណតរថយន្តនៅចំណុចខាងលើនេះ ។



Scanned with CamScanner

ក្រោយពីលោកឧកញ៉ា [redacted] ភាព និងលោក [redacted] គង់ ធ្វើវិនិយោគរួមគ្នាក្នុងការធ្វើអាជីវកម្មនៅចំណុចបេនចំណតរថយន្តខាងលើរួចហើយ ស្រាប់តែឈ្មោះ [redacted] សុខា បានចាក់ដីនៅលើទីតាំងចំណតរថយន្តខាងលើនេះមិនអាចឲ្យឡានចូលចតបាន និងធ្វើឲ្យទឹកហៀរទៅលើផ្ទះប្រជាពលរដ្ឋដែលរស់នៅប៉ែកខាងជើង បន្ទាប់មកឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រៃវែង បានចេញលិខិតជម្រាបលេខ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ឲ្យឈ្មោះ [redacted] សុខា ឈូសឆាយទំនួកដីនោះចេញ តែឈ្មោះ [redacted] សុខា មិនព្រម ទើបអាជ្ញាធរខេត្ត ស្រុក ដោយមានការសម្របសម្រួលពីលោក [redacted] សុផុន ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រៃវែង ចុះទៅធ្វើការឈូសឆាយចេញតែម្តង ។

ការស្នើសុំលុបលិខិតលេខ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង ខ្លួនជាតំណាងឲ្យអភិបាល នៃគណៈអភិបាលខេត្តព្រៃវែង មិនឯកភាពឲ្យធ្វើការលុបនោះទេ គឺខ្លួនសុំរក្សាលិខិតនោះនៅជាធរមានដដែល ដោយហេតុថា លេខ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ មានឯកសារយោងគ្រប់គ្រាន់ទៅតាមផ្លូវច្បាប់ ។

ជាសំណូមពរចុងក្រោយ ក្នុងនាមខ្លួនជាអ្នកតំណាង ស្នើសុំតុលាការមានវិធានការតាមផ្លូវច្បាប់ទៅលើភាគីខាងដើមចោទ ដោយឲ្យភាគីខាងដើមចោទរុះរើតូបលក់បាយចេញពីដីចំណតរថយន្តទំហំ ២០មx៣៤ម ។

អ្នកតំណាងលោក [redacted] **សុធា** និងលោក [redacted] **សុខជា** បានធ្វើការអះអាងថា ខ្លួនសុំឯកភាពតាមសេចក្តីថ្លែងការណ៍របស់លោក [redacted] **វ៉ន** ទាំងស្រុង ។

**១.៤.៣.ការអះអាងរបស់សាក្សី**

-សាក្សីឈ្មោះ [redacted] **ចាន់សុផល** បានធ្វើការអះអាងថាៈ ខ្លួនមករស់នៅនោះតាំងពីមិនទាន់មានផ្សារ ហើយទាល់តែគេរៀបចំផ្សារហើយ ទើបឃើញរ៉ឺម៉កម៉ូតូ និងឡានមកចតនៅបេនចំណត ។

-សាក្សីឈ្មោះ [redacted] **គន្ធា** បានធ្វើការអះអាងថា ខ្លួនឃើញដើមចោទមករស់នៅលើដីនេះតាំងពីយូរណាស់មកហើយ ។

ដីនេះឈ្មោះ [redacted] សុខា ជាអ្នកគ្រប់គ្រង ហើយការគេមកឈូសឆាយ ខ្លួនមិនបានដឹងនោះទេ ។

ដីនេះពីមុនជាជង្ហុកជ្រៅ លុះដល់ឈ្មោះ [redacted] សុខា គាត់ចាក់ដីពេញ ទើបមានឡានមកចត ។

ដីនេះខ្លួនមិនដឹងទំហំនោះទេ គ្រាន់តែដឹងថា ដីធំ ។ ពេលគេចុះទៅខ្លួនអត់ដឹងទេ ព្រោះខ្លួននៅកន្លែងលក់ ។

រឿងលិខិតសជណ ខ្លួនមិនដឹងទេ ។

ពីមុនខ្លួនលក់នៅកន្លែងនោះ តែតាំងពីតាសុខា មកធ្វើការ៉ាស់សាំង ខ្លួនក៏ឈប់លក់នៅទីនោះ ។



Scanned with CamScanner

-សាក្សីឈ្មោះ [redacted]ផល បានធ្វើការអះអាងថា ខ្លួនឃើញដើមចោទមករស់នៅទីនោះមុនបង្កើតផ្សារ ហើយពីមុនមានជង្ហុកជ្រៅណាស់ តែពេលដើមចោទចាក់ដីពេញ ទើបមានឡានមកចត ។ នៅកន្លែងនោះដើមចោទឈ្មោះ [redacted] សុខា បានសាងសង់តូបលក់ដូរទំហំក្បាល៥ម៉ែត្រ បណ្តោយ១០ម៉ែត្រ ។

ផ្ទះខ្លួននៅខាងកើតផ្សារ រីឯផ្ទះរបស់ដើមចោទនៅខាងលិចផ្សារ ។

កន្លងមកមានគេទៅហាមឃាត់ដើមចោទមិនឲ្យចាក់ដី ដោយគេថាជាចំណតបេនឡាន តែមិនដឹងខាងណានោះទេ ។

## ២. ផ្នែកសំអាងហេតុ

## ក្រោយបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា:

២-១. វិវាទរវាងដើមចោទឈ្មោះ [redacted] សុខា និងចុងចម្លើយជាអភិបាល នៃគណៈអភិបាលខេត្តព្រៃវែង គឺជាវិវាទរដ្ឋបាល ហើយតាមមាត្រា១២៨ថ្មី កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "អំណាចតុលាការគ្របដណ្តប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង" ដូច្នេះវិវាទនេះជាសមត្ថកិច្ចរបស់សាលាដំបូងខេត្តព្រៃវែង ។

២-២. តាមពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] **សុខា** បានប្តឹងសុំឲ្យតុលាការបដិសេធលិខិតជូនដំណឹងលេខ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង ចោលទាំងស្រុង ដោយសំអាងហេតុថា ដីទំហំ២០មx៣៤ម ស្ថិតនៅចំណុចភូមិ៤ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង ម៉ុំស្ថានីយប្រេងឥន្ធនៈជិតផ្សារអ្នកលឿង ដែលឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រៃវែង ដាក់ធ្វើជាបេនចំណតរថយន្តនោះ គឺមិនត្រឹមត្រូវនោះទេ ដោយហេតុថា ដីនេះជាដីកម្មសិទ្ធិរបស់ខ្លួន ដែលបានកាន់កាប់រកស៊ីលក់ដូរបាយម្ហូបតាំងពីឆ្នាំ១៩៨៤ តាំងពីមិនទាន់មានផ្សារនៅឡើយ ដោយផ្សារទើបតែបង្កើតនៅឆ្នាំ១៩៩៦ ហើយពេលដែលខ្លួនមកលក់សម្ល ស្ថានីយ៍ប្រេងក៏មិនទាន់មានដែរ ។ ការលើកឡើងនេះពុំមានលក្ខណៈត្រឹមត្រូវនោះទេ ដោយហេតុថា:

- ដីបេនចំណតរថយន្តទំហំ២០មx៣៤ម នៅចន្លោះស្ថានីយ៍ប្រេងឥន្ធនៈមុខសណ្ឋាគារសុវណ្ណពេជ្រ ស្ថិតនៅចំណុចភូមិ៤ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង ត្រូវបានរដ្ឋបាលខេត្តព្រៃវែង បានចុះបញ្ជីជាចំណតរថយន្តជើងគោក តាមដីកាស្តីពីការកំណត់ទីតាំងចំណតជើងគោកជើងទឹកអ្នកលឿងលេខ៣៥/២០០៣ ដ.ក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៣ និងគំនូសព្រាងចំណតរថយន្តចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៣ ។



Scanned with CamScanner

- តាមលិខិតលេខ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង បានជូនដំណឹងទៅឈ្មោះ [redacted] សុខា ឲ្យធ្វើការឈូសឆាយដីដែលបានចាក់បំពាននៅចំណតរថយន្ត នៅចន្លោះស្ថាននីយ៍ប្រេងឥន្ធនៈមុខសណ្ឋាគារ សុវណ្ណពេជ្រ ដោយហេតុថា ឈ្មោះ [redacted] សុខា បានចាក់ដីនៅលើទីតាំងចំណតរថយន្ត មិនអាចឲ្យឡានចូលចតបាន និងធ្វើឲ្យទឹកហៀរទៅលើផ្ទះប្រជាពលរដ្ឋ ដែលរស់នៅប៉ែកខាងជើង ។
- ការកាន់កាប់ដីនៅចំណតរថយន្ត នៅចន្លោះស្ថាននីយ៍ប្រេងឥន្ធនៈ មុខសណ្ឋាគារ សុវណ្ណពេជ្រ របស់ដើមចោទ ពុំមានឯកសារបញ្ជាក់ពីកម្មសិទ្ធិច្បាស់លាស់ណាមួយនោះទេ ក្រៅតែពីការអះអាងរបស់ដើមចោទ ក៏ដូចជាការអះអាងរបស់សាក្សី ។

២-៣. ដូច្នេះលិខិតលេខ៣១៣/សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់អភិបាល នៃគណៈអភិបាលខេត្តព្រៃវែង មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ គឺដើម្បីការពារទ្រព្យសម្បត្តិរបស់រដ្ឋ និងការពារផលប្រយោជន៍សាធារណៈ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅសងខាងចំណតបេន ។

២-៤. ការលើកឡើងរបស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ មានលក្ខណៈសមស្របទៅតាមបណ្តឹងទាមទាររបស់ដើមចោទ តែមិនមានលក្ខណៈត្រឹមត្រូវទៅតាមគតិច្បាប់នោះទេ ។

២-៥. សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ស្នើសុំឲ្យតុលាការច្រានចោលពាក្យបណ្តឹងទាមទាររបស់ដើមនោះ មានលក្ខណៈត្រឹមត្រូវ និងដើម្បីការពារផលប្រយោជន៍សាធារណៈ ។ គប្បីតុលាការពិចារណា ។

២-៦. ការលើកឡើងរបស់អ្នកតំណាងចុងចម្លើយ មានលក្ខណៈត្រឹមត្រូវ និងសមហេតុសមផល ដែលអាចឲ្យតុលាការពិចារណា និងសម្រេចបាន ។

២-៧. ចំពោះប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមបញ្ញត្តិមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៣-ផ្នែកសេចក្តីសម្រេច

### សេចក្តីសម្រេចបញ្ចប់

៣-១. ច្រានចោលពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] សុខា ។

៣-២. រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់ទុករួចហើយ ។

៣-៣. សាលក្រមនេះបានប្រកាសជាសាធារណៈនៅថ្ងៃសុក្រ ៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខដើមចោទ ,មេធាវីតំណាងអាណត្តិឲ្យដើមចោទ និងអ្នកតំណាងឲ្យចុងចម្លើយ បើកផ្លូវឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ព្រៃវែង, ថ្ងៃទី ០៣ ខែ [illegible] ឆ្នាំ ២០២១
ក្រឡាបញ្ជី
[redacted]

ចៅក្រមជំនុំជម្រះ
[redacted]